002/19-09-2007-ECCC/TC
E1/47

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 03 / 2012
ម៉ោង (Time/Heure) : 14 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៣៥

រៀបចំដោយ: សែ កុលវុឌ្ឍី និង Matteo CRIPPA

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត, លោក ចាន់ ដារារស្មី, លោក Vincent DE WILDE D'ESTMAEL (រសៀល), លោក Tarik Abdulhak |
| ជនជាប់ចោទ៖ អៀង សារី , នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel Pestman, លោក Andrew Ianuzzi |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្ដម ,លោក Michael Karnavas |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta Guisse |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth Simonneau-Fort, លោកស្រី ជេត វណ្ណលី, លោក វ៉េន ពៅ, លោក ឡោ ជុនធី, លោក គីម ម៉េងឃី, លោកស្រី ទីស្រ៊ីនណា, លោក ហុង គីមសួន, លោក Barnabé NEKUIE. |
| ផ្សេងៗ៖ កញ្ញា Zuzana KOVALOVA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៤.៥៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ៥៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការកែប្រែសេចក្តីសម្រេចផ្ទាល់មាត់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ | អង្គជំនុំជម្រះ | ៩.០៥ | ៩.០៩ |
| ការធ្វើសេចក្តីសន្និដ្ឋានជំទាស់ទៅលើការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ | មេធាវីការពារឱ្យខៀវ សំផន | ៩.០៩ | ១០.១០ |
| ការលះបង់សិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមដោយផ្ទាល់នៅបន្ទប់សវនាការ | មេធាវីការពារឱ្យ អៀង សារី<br>មេធាវីការពារឱ្យ នួន ជា | ១០.០៨<br>១២.០២ | ១០.១០<br>១២.០៣ |
| ការជូនដំណឹងរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី | ១០.០៩ | ១០.១០ |
| ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនិងការជំទាស់របស់មេធាវីការពារក្តី | សហព្រះរាជអាជ្ញា | ១០.៣៥ | ១៦.០៣ |

| | | | |
|---|---|---|---|
| មេធាវីការពារក្ដីស្នើសុំពេលវេលាបន្ថែមក្នុងការឆ្លើយតបទៅនឹងចម្លើយតប | មេធាវីការពារឱ្យ អៀង សារី<br>មេធាវីការពារឱ្យ នួន ជា<br>មេធាវីការពារឱ្យ ខៀវ សំផន<br>អង្គជំនុំជម្រះ | ១៦.០៣ | ១៦.០៧ |
| ការបញ្ជាក់អំពីកាលវិភាគសវនាការ | សហព្រះរាជអាជ្ញា<br>មេធាវីការពារឱ្យ នួន ជា<br>អង្គជំនុំជម្រះ | ១៦.០៦ | ១៦.១៥ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការកែប្រែសេចក្ដីសម្រេចផ្ទាល់មាត់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២**

អាស្រ័យដោយមានភាពលំបាកចំពោះការបកប្រែភាសាអង់គ្លេស អង្គជំនុំជម្រះបានធ្វើការបញ្ជាក់ថា នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះបានកំណត់ថា អង្គជំនុំជម្រះនឹងមិនផ្ដល់ពេលវេលាឱ្យធ្វើការពិភាក្សាអំពី “ការពិនិត្យតម្លៃនៃឯកសារ” (ជំនួសឱ្យការបកប្រែពីមុនថា “ការវាយតម្លៃនៃភស្តុតាង”) នោះទេ។ បញ្ហាផ្សេងៗអាចនឹងត្រូវបានលើកឡើងដូចជាឯកសារដែលបានយកមកដេញដោលនៅពេលសវនាការ ប៉ុន្តែអាចលើកឡើងនៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់។

**ការធ្វើសេចក្ដីសន្និដ្ឋានជំទាស់ទៅលើការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ**

មេធាវីការពារឱ្យ ខៀវ សំផន បានធ្វើសេចក្ដីសន្និដ្ឋានជំទាស់ទៅលើការដាក់ឯកសារផ្សេងៗដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**ការលះបង់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការចូលរួមដោយផ្ទាល់នៅបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី និង នួន ជា បានលះបង់សិទ្ធិរបស់ពួកគេក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ។

**ការជូនដំណឹងរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ**

សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានជូនដំណឹងថាពួកគេនឹងមិនមានការជំទាស់ចំពោះការដាក់ឯកសារផ្សេងៗដោយមេធាវីការពារក្ដីនោះទេ។

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់មេធាវីការពារក្ដី**

សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានឆ្លើយតបទៅនឹងការជំទាស់ទៅលើការដាក់ឯកសារដោយក្រុម

មេធាវីការពារក្តី។

**សំណើសុំបន្ថែមពេលវេលាក្នុងការឆ្លើយតបទៅនឹងចម្លើយតបដោយក្រុមមេធាវីការពារក្តី**

ក្រុមមេធាវីការពារក្តីបានស្នើសុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះបានទទួលយកសំណើនេះ ហើយអនុញ្ញាតិឲ្យក្រុមមេធាវីការពារក្តីទាំងអស់មានរយៈពេល មួយម៉ោងក្នុងការឆ្លើយតប។

**ការបញ្ជាក់អំពីកាលវិភាគសវនាការ**

ដោយមានសំណើរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថាអង្គជំនុំជម្រះនឹងអនុវត្តទៅតាមអ្វីដែលបានកំណត់នៅក្នុងកាលវិភាគសវនាការដែលបានចេញកាលពីពេលមុនដែលមានលេខ E172/5។ ទោះបីជាយ៉ាងណាក៏ដោយ កាលវិភាគសវនាការសម្រាប់សប្តាហ៍នេះអាចប្រហែលជានឹងមិនបន្តទៅសប្តាហ៍ក្រោយនោះទេ។

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី (ម៉ោង ១០.១០) និង នួន ជា (ម៉ោង ១២.០៣) ទៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរមានភ្ជាប់មកជាមួយកំណត់ហេតុនេះ) ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ៩ ព្រឹក នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២។

**ការលើកពេលវេលាសវនាការបន្ត៖**

សវនាការនឹងបន្តនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលឧត្តម Matteo CRIPPA